នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ព័ត៌មានពិស្តារនៃការដាក់ឯកសារ

សំណុំរឿងលេខ	:	០០២/១៩-០៩-២០០៧-អវតក/អជសដ
ដាក់ទៅ	:	អង្គជំនុំជម្រះសាលាដំបូង
ថ្ងៃដាក់	:	ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤
ភាគីអ្នកដាក់	:	សហព្រះរាជអាជ្ញា
ភាសាដើម	:	អង់គ្លេស

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jan-2014, 09:38
CMS/CFO: Sann Rada

ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងសារណាររបស់ នួន ជា និង ខៀវ សំផន ទាក់ទងទៅនឹងការកំណត់កាលបរិច្ឆេទសវនាការរបស់តុលាការ និងការពិនិត្យឡើងវិញ អំពីសម្បទា

អ្នកដាក់ឯកសារ:
សហព្រះរាជអាជ្ញា
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

អ្នកទទួលឯកសារ:
អង្គជំនុំជម្រះសាលាដំបូង
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

ចម្លងជូន:
ជនជាប់ចោទ
នួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Arthur VERCKEN
លោកស្រី Anta GUISSE

ចម្លើយតប

ក. សេចក្តីផ្តើម

១- កាលពីថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានស្នើឲ្យក្រុមមេធាវីការពារក្តី "ដាក់សារណាជាលាយលក្ខណ៍អក្សរខ្លី ត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៤ ដោយបញ្ជាក់ថា តើពួកគេយល់ឃើញថា តើស្ថានភាពសុខភាពរបស់កូនក្តីរបស់ពួកគេម្នាក់ៗ មានការផ្លាស់ប្តូរដែរ ឬយ៉ាងណា ហើយតើមានភាពចាំបាច់ដែរឬទេ ក្នុងការវាយតម្លៃជាថ្មីឡើងវិញអំពីសម្បទាក្នុងការចូលរួមសវនាការរបស់ពួកគាត់ និង/ឬមានសមត្ថភាពផ្នែករូបរាងកាយរបស់ពួកគាត់ ក្នុងការចូលរួមទៅតាមកាលបរិច្ឆេទសវនាការទាំងអស់ដែលបានគ្រោងទុក"[1]។

២- កាលពីថ្ងទី១៥ ខែមករា ឆ្នាំ២០១៤ ក្រុមមេធាវីការពាររបស់ នួន ជា និង ខៀវ សំផន បានដាក់នូវចម្លើយតបរបស់ខ្លួន។ ដោយពុំមានការលើកឡើងថា កូនក្តីរបស់ខ្លួនមិនមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមសវវនាការក្នុងសំណុំរឿងលេខ០២/០២នោះឡើយ។ ប៉ុន្តែក្រុមនីមួយៗបានស្នើសុំដាច់ដោយឡែកពីគ្នាឲ្យកាត់បន្ថយកាលវិភាគនៃសវនាការ[2]។ លើសពីនេះ មេធាវីការពារក្តីរបស់ នួន ជា បានស្នើឲ្យតែងតាំងអ្នកជំនាញមួយរូប ដើម្បីដឹកនាំធ្វើការពិនិត្យសុខភាពតាមវេជ្ជសាស្ត្រឲ្យបានល្អិតល្អន់ ដើម្បីគោលបំណងធ្វើការវាយតម្លៃអំពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ[3]។

ខ. ការកាត់បន្ថយបន្តិចនូវពេលវេលាក្នុងការធ្វើសវនាការ គឺជាការសមស្រប នៅក្នុងកាលៈទេសៈទាំងនេះ

៣- សហព្រះរាជអាជ្ញាមិនមានការជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តី ដែលសុំឲ្យកាត់បន្ថយរយៈពេលសវនាការក្នុងថ្ងៃនីមួយៗ នៅក្នុងអម្ពុពេលធ្វើការពិភាក្សាសម្រេចលើសំណុំរឿងលេខ០០២/០១

---

[1] ឯកសារលេខ **E301/5** ផែនការការងាររបស់អង្គជំនុំជម្រះសាលាដំបូងសំរាប់សំណុំរឿងលេខ០០២/០២ និងការកំណត់កាលបរិច្ឆេទនៃការដាក់ឯកសារនាពេលខាងមុខ, ចុះថ្ងៃទី២៤ ធ្នូ ២០១៣។

[2] ឯកសារលេខ **E301/7** ចម្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូង សុំឲ្យដាក់សារណាស្តីពីការពិនិត្យឡើងវិញអំពីសម្បទារបស់ នួន ជា, ចុះថ្ងៃទី១៥ មករា ២០១៤។ ឯកសារលេខ **E301/6** ការជូនព័ត៌មានពីមេធាវីការពារក្តីរបស់លោក ខៀវ សំផន ស្តីពីសម្បទា និង និងវិធីសសាស្ត្រក្នុងការការរៀបចំសវនាការ, ចុះថ្ងៃទី១៥ មករា ២០១៤។

[3] ឯកសារលេខ**E301/7** ចម្លើយតបទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងឲ្យដាក់សារណាស្តីពីការពិនិត្យឡើងវិញអំពីសម្បទារបស់ នួន ជា ក្នុងការចូលរួមសវនាការ, ចុះថ្ងៃទី១៥ មករា២០១៤, កថាខណ្ឌពីទី១១-១២, និងកថាខណ្ឌទី១៥។

តាមរយៈការដាក់សេចក្តីសន្និដ្ឋានរបស់ភាគី ស្តីពីបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ០០២/០១។ ការកាត់បន្ថយបែបនេះ នឹងជួយដល់អង្គជំនុំជម្រះ និងគ្រប់ភាគីទាំងអស់ ឲ្យបំពេញភារកិច្ចផ្សេងៗទៀតរបស់ខ្លួនក្រៅពីសវនាការនៅក្នុងសំណុំរឿងលេខ០០២/០២។

៤- ដូចដែលខាងអយ្យការបានទទួលស្គាល់រួចហើយនៅកិច្ចប្រជុំដើម្បីរៀបចំសវនាការកាលពីថ្ងៃទី១១ និង ១២ ខែធ្នូ ឆ្នាំ២០១៣, ការកាត់បន្ថយរយៈពេលនៃសវនាការ នៅក្នុងសំណុំរឿងលេខ០០២ /០២ នៅក្នុងពេលដែលសាលក្រមកំពុងតែត្រូវបានបង្កើយនៅក្នុងសំណុំរឿងលេខ០០២/០១ គឺជាវិធានការសមហេតុផល ដោយសារមានការកើនឡើងនូវទាមទារថាការអនុវត្តនូវភារកិច្ចទាំងនេះក្នុងពេលជាមួយគ្នាទំនងជានឹងកើតមានទៅលើធនធានរបស់អង្គជំនុំជម្រះ។ បន្ទាប់ពីសាលក្រមត្រូវបានចេញហើយនោះ ដោយមិនគិតពីលទ្ធផល បណ្តឹងសាទុក្ខដែលចេញមកពីភាគីផ្សេងៗ ឬមួយក៏ចេញមកពីគ្រប់ភាគីទាំងអស់ទំនងជានឹងកើតមាន។ បើសិនជាសាលក្រមត្រូវបានចេញនៅត្រឹមដំណាច់ខែមិថុនា ឆ្នាំ២០១៤ ដូចដែលបានប៉ាន់ស្មានទុកនោះ ក្នុងពេលភ្លាមៗបន្ទាប់ពីនោះមក ភាគីនានាទំនងជានឹងត្រូវជាប់រវល់នៅក្នុងការរៀបចំធ្វើការជូនដំណឹងអំពីបណ្តឹងសាទុក្ខ ការដាក់សារណាលើបណ្តឹងសាទុក្ខ និងការឆ្លើយតបនានា។ នេះគឺប្រាកដជាត្រូវការនូវការកាត់បន្ថយរយៈពេលនៃសវនាការ ក្នុងសំណុំរឿងលេខ ០០២/០២ ដើម្បីឲ្យបានស្របទៅតាមភាគីនានា ជាពិសេសទៅនឹងទំហំបន្ទុកការងារនៅក្នុងដំណើរការលើបណ្តឹងសាទុក្ខ។ ការកាត់បន្ថយណាមួយ គួរតែបានធ្វើជាបន្តទៅទៀតរហូតដល់រាល់សារណាឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខទាំងអស់ក្នុងសំណុំរឿងលេ០០២/០១ ត្រូវបានដាក់រួចរាល់។ ត្រង់ចំណុចនោះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សំណុំរឿងលេខ០០២/០២ គួរតែបានត្រឡប់មកធ្វើជាកាលវិភាគនៃសវនាការពេញម៉ោងវិញ លុះត្រាតែមានការបង្ហាញថាកាលវិភាគដែលមានការកម្រិតជាងនេះមានភាពចាំបាច់ ដើម្បីផលប្រយោជន៍ចំពោះសុខភាពរបស់ជនជាប់ចោទស្របទៅតាមស្ថានភាពរបស់ពួកគេនៅពេលនោះ។ ដោយសារការដាក់សារណាលើបណ្តឹងសាទុក្ខនានាមិនទំនងជានឹងត្រូវបានធ្វើបង្កើយបានទេរហូតដល់ចុងឆ្នាំ២០១៤នោះ ការវាយតម្លៃ ឬការកំណត់ណាមួយអំពីស្ថានភាពរបស់ជនជាប់ចោទក្នុងការចូលរួមនៅក្នុងសវនាការដោយពេញម៉ោងតាមកាលវិភាគកំណត់បន្ទាប់ពីសារណាលើបណ្តឹងសាទុក្ខ អាចត្រូវបានធ្វើឡើងមុនពេលកំណត់នៅក្នុងពេលនេះ ដោយសារស្ថានភាពសុខភាពរបស់ជនជាប់ចោទអាចប្រែប្រួលនៅក្នុងរយៈពេលមានសារៈសំខាន់នេះ។

គ. ការវាយតម្លៃមួយយ៉ាងល្អិតល្អន់អំពីសម្បទាក្នុងការចូលរួមសវនាការ របស់ ឡូន ជា នាពេលបច្ចុប្បន្ននេះ គឺមិនមានភាពចាំបាច់ និងមិនអនុញ្ញាតឲ្យទេ

៥- អង្គជំនុំជម្រះនានានៃតុលាការ ICTY បានបញ្ជាក់ថា ជនជាប់ចោទណាម្នាក់នឹងត្រូវបានគេចាត់ទុកថាពុំមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការបាន ប្រសិនជាជននោះមិនអាចអនុវត្តនូវសិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវការជំនុំជម្រះក្តីដោយត្រឹមត្រូវបានដោយប្រសិទ្ធភាព គឺដោយសារតែសមត្ថភាពផ្សេងៗត្រូវបានខូច។ ការវាយតម្លៃអំពីសម្បទារបស់ជនជាប់ចោទ គឺមិន "តម្រូវ[]ឲ្យជនជាប់ត្រូវតែមានសមត្ថភាពក្នុងការអាច*យល់ដឹងបានទាំងអស់ទាំងស្រុង*អំពីកិច្ចដំណើរការនីតិវិធីនៃការជំនុំជម្រះក្តីនោះទេ"[4]។ ផ្ទុយទៅវិញ ជាការចាំបាច់គឺតម្រូវឲ្យបំពេញឲ្យបាននូវបទដ្ឋានជាអប្បរមាមួយគ្រប់តាមលក្ខខណ្ឌតម្រូវ នៅពេលដែលជនជាប់ចោទអាចធ្វើការឆ្លើយតបនឹងបទចោទប្រកាន់, អាចផ្តល់សក្ខីកម្ម, ធ្វើការណែនាំដល់មេធាវីការពារក្តី, និងអាចយល់អំពីលក្ខណៈនៃបទចោទប្រកាន់នានា, និងអំពីផលវិបាកផ្សេងៗនៃបទចោទប្រកាន់ទាំងនោះនៅក្នុងកម្រិតមួយ ដែលអាចឲ្យជនជាប់ចោទមានលទ្ធភាពចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបាន និងអាចអនុវត្តនូវសិទ្ធិទាំងនោះបាន[5]។

៦- ការសួរដេញដោលអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ គឺមិនត្រូវបានផ្តួចផ្តើមថាជាសិទ្ធិនោះទេ។ ដើម្បីចាប់ផ្តើមធ្វើការសួរដេញដោលនេះ តុលាការ ICTY បានបង្ហាញឲ្យឃើញថាត្រូវតែមាន "មូលហេតុគ្រប់គ្រាន់" ដើម្បីចោទសួរសំណួរអំពីសមត្ថភាពរបស់ជនជាប់ចោទក្នុងការយល់បានអំពីដំណើរការនីតិវិធីដែលប្រឆាំងចំពោះពួកគេ[6]។ សារណារបស់មេធាវីការពារក្តីបានលើកឡើងដោយមិនត្រឹមត្រូវថា បន្ទុកក្នុងការបង្ហាញភ័ស្តុតាងទាក់ទងអំពីសម្បទារបស់ជនជាប់ចោទ មិនស្ថិតនៅលើភាគីជាពិសេសណាមួយនោះឡើយ[7]។ មេធាវីការពារក្តី គឺជាអ្នកត្រូវមានបន្ទុកក្នុងការ

---

[4] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Pavle Strugar,* សំណុំរឿងលេខ, Case No. IT-01-42-T, សេចក្តីសម្រេចស្តីពី ញត្តិ របស់មេធាវីការពារក្តីដែលស្នើសុំឲ្យបញ្ឈប់កិច្ចដំណើរការនីតិវិធី (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៦ ឧសភា ២០០៤ ("សេចក្តីសម្រេចលើករណីរបស់ Strugar ") ត្រង់កថាខណ្ឌទី៤៨ (សង្កត់ន័យនៅក្នុងច្បាប់ដើម)។

[5] សេចក្តីសម្រេចលើករណីរបស់ Strugar , កំណត់សម្គាល់លេខ ៤ *ខាងដើម* ត្រង់កថាខណ្ឌលេខ៣៦។

[6] *ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង Stanišić,*សំណុំរឿងលេខ Case No. IT-03-69, សេចក្តីសម្រេចលើញត្តិស្នើសុំរបស់មេធាវីការពារក្តីរបស់ Stanišić ស្តីពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៧ មេសា ២០០៦ ("សេចក្តីសម្រេចលើករណីរបស់ Stanišić")។សេចក្តីសម្រេចលើករណីរបស់ Strugar , កំណត់សម្គាល់លេខ ៤ *ខាងដើម* ត្រង់កថាខណ្ឌលេខ២៥។

[7] ឯកសារលេខ E301/7, កំណត់សម្គាល់លេខ ២ *ខាងដើម*។

បង្ហាញឲ្យឃើញថា មូលហេតុគ្រប់គ្រាន់ដូចនេះ គឺអត្ថិភាពដើម្បីតម្រូវឲ្យចាប់ផ្តើមធ្វើការសួរដេញដោលអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ[8] ។

៧- ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ប្រទេសទីម័រខាងកើត) បានសម្រេចថា បើតុលាការយល់ឃើញថា "*មានក្តីបារម្ភដ៏សំខាន់មួយ* អំពីសមត្ថភាពរបស់ [ជនជាប់ចោទ] ក្នុងការចូលរួមសវនាការ" ហើយក្តីបារម្ភបែបដូច្នេះមានមូលដ្ឋានរបស់វាឋិតនៅលើភ័ស្តុតាងដ៏សំខាន់នោះវា គឺជាការសមស្របហើយ ដែលត្រូវធ្វើការសាកសួរអំពីសមត្ថភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ[9]។ យ៉ាងណាក៏ដោយ ក្នុងការដែលមិនមានវត្តមាននៃក្តីបារម្ភដ៏សំខាន់ណាមួយទេ នោះការសាកសួរបន្ថែមអំពីសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ គឺជាការដែលធ្វើឡើងដោយមិនមានសំអាងភ័ស្តុតាង និងមិនមានការចាំបាច់នោះឡើយ។

៨- នៅក្នុងស្ថានភាពទាំងឡាយណាដែលសម្បទាក្នុងការចូលរួមសវនាការ វាគឺជាបញ្ហាមួយ ហើយវាមានការប្រែប្រួលខុសៗគ្នាដ៏សំខាន់ រវាងទស្សនៈនានារបស់អ្នកជំនាញ និងភ័ស្តុតាងខាងផ្នែកវេជ្ជសាស្ត្រ នោះវាអាចជាការចាំបាច់ក្នុងការចាត់តាំងអ្នកជំនាញបន្ថែម ឬមួយក៏ត្រូវធ្វើការសួរដេញដោលបន្ថែមទៀត[10]។ យ៉ាងណាក៏ដោយ នៅក្នុងករណីបច្ចុប្បន្នរបស់ នួន ជា វាពុំមានអត្ថិភាពនៃការប្រែប្រួលខុសៗគ្នាដ៏សំខាន់បែបដូច្នេះនោះឡើយ គឺថាទស្សនៈទាំងឡាយរបស់អ្នកជំនាញខាងផ្នែកវេជ្ជសាស្ត្រមានលក្ខណៈត្រូវគ្នាយ៉ាងច្រើន ហើយបុរេនិមិត្តបច្ចុប្បន្នរបស់ជនចាប់ចោទ នួន ជា មានលក្ខណៈល្អប្រសើរ[11]។

៩- ការអះអាងរបស់មេធាវីការពារក្តីដែលពាក់ព័ន្ធនឹងស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា មិនបានបង្ហាញអំពីមូលហេតុគ្រប់គ្រាន់ ដើម្បីនឹងធ្វើការសាកសួរទៅលើសម្បទារបស់គាត់ក្នុងការចូលរួម

---

[8] សេចក្តីសម្រេចលើករណីរបស់ Stanišić, កំណត់សម្គាល់លេខ ៤ *ខាងដើម*។

[9] *អគ្គរដ្ឋអាជ្ញារងសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ទល់នឹង Josep Nahak,* សំណុំរឿងលេខ 01A/2004, ការយល់ឃើញ និង ដីកាបង្គាប់ពីសមត្ថភាពរបស់ចុងចោទ Nahak ឲ្យចូលរួមសវនាការ (ក្រុមប្រឹក្សាពិសេសសម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ (ប្រទេសទីម័រខាងកើត)), ១ មីនា ២០០៥ ត្រង់កថាខណ្ឌ ៤៩។

[10] *រដ្ឋអាជ្ញា ទល់នឹង Vladimir Kovačević,* សំណុំរឿងលេខ IT-01-42/2-I, សំណៅសាធារណៈស្តីពីសេចក្តីសម្រេចលើសម្បទារបស់ជនជាប់ចោទ ឲ្យចូលរួមសវនាការ និង ផ្តល់ចម្លើយ (អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY), ១២ មេសា ២០០៦ ត្រង់កថាខណ្ឌ ១៧។

[11] ជាឧទាហរណ៍ សូមអាន ឯកសារលេខ **E10/166** របាយការណ៍វេជ្ជសាស្ត្រប្រចាំសប្តាហ៍របស់ នួន ជា ចុះថ្ងៃទី ១៦-០១-២០១៤, ១៦ មករា ២០១៤, ដោយបានកត់សម្គាល់ថា នួន ជា មាន "ស្ថានភាពសុខភាពទូទៅល្អប្រសើរ - good haemodynamic condition"។

សវនាការនោះឡើយ។ ការអះអាងទាំងនេះ គឺគ្រាន់តែជាការលើកឡើងនូវភ័ស្តុតាងសាជាថ្មីឡើងវិញ ដែលត្រូវបានលើក ជាតួយ៉ាង ចេញពីការសួរដេញដោលរបស់អ្នកជំនាញ តាំងពីខែមីនា ឆ្នាំ២០១៣ មកម្ល៉េះ ដែលនៅក្នុងនោះ នួន ជា ត្រូវបានគេចាត់ទុកថាសមនឹងមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ។ វាមិនមានភ័ស្តុតាងថ្មីៗខាងផ្នែកវេជ្ជសាស្ត្រដែលបញ្ជាក់អំពីការខូចខាតស្ថានភាព [សុខភាព] ត្រូវបានគេផ្តល់ឲ្យនៅក្នុងការដាក់ជូនរបស់មេធាវីការពារក្តីនោះទេ។ លើសពីនេះ តេស្តខាងផ្នែកវេជ្ជសាស្ត្រដែលបានធ្វើឡើងចាប់តាំពីមានការសួរដេញដោល កាលពីខែមីនា ឆ្នាំ២០១៣ មកនោះ គឺវាមិនបានបញ្ជាក់ពីការខូចខាតធំដុំខាងស្ថានភាពផ្លូវកាយរបស់ នួន ជា នោះទេ។

១០- អង្គជំនុំជម្រះនានានៃតុលាការ ICTY បានសម្រេចថា ការពិចារណាអំពីភាពឆាប់រហ័ស នឹងបន្ថយការវាយតម្លៃបន្ថែមទៀតលើសម្បទារបស់ជនជាប់ចោទក្នុងការចូលរួមសវនាការ ក្នុង កាលៈទេសៈដែលមិនមានការព្រួយបារម្ភច្រើនអំពីសមត្ថភាពរបស់ជនជាប់ចោទ ក៏ដូចជា ការដែលមិនមានមូលហេតុគ្រប់គ្រាន់ណាមួយដែលអាចនាំទៅដល់ក្តីបារម្ភបែបដូច្នោះទេ ៖

> *អង្គជំនុំជម្រះមាន...កាតព្វកិច្ច...ធានាថាសវនាការត្រូវមានយុត្តិធម៌ និងឆាប់រហ័ស។ ក្នុងរយៈកាលប៉ុន្មានខែកន្លងមកនេះ អង្គជំនុំជម្រះបានចំណាយលើកិច្ចប្រឹងប្រែងរបស់ខ្លួនយ៉ាងច្រើនក្នុងការផ្តល់នូវផាសុកភាពទាំងឡាយ ដើម្បីសម្របសម្រួលនូវក្តីបារម្ភនានាខាងផ្នែកសុខភាពរបស់ជនជាប់ចោទ។ ការណ៍នេះមានរួមលើសពីអ្វីៗទាំងអស់នោះ គឺលទ្ធភាពនៃការកាត់បន្ថយនូវចំនួនវគ្គសវនាការ... និងលទ្ធភាពសម្រាប់ឲ្យជនជាប់ចោទមានការប្រើប្រាស់នូវការប្រជុំតាមប្រព័ន្ធសោតទស្សន៍...។ វានៅមានភាពមិនស្របគ្នាដោយអន្លើជាប់ជានិច្ច រវាងការអះអាង[របស់ជនជាប់ចោទ] និងការសួរដេញដោលខាងផ្នែកវេជ្ជសាស្ត្រ។ អង្គជំនុំជម្រះចាំបាច់ត្រូវរកឲ្យឃើញនូវតុល្យភាពដ៏ត្រឹមត្រូវមួយ រវាងការតាមឃ្លាំមើលនូវការវិវត្តន៍ខាងផ្នែកសុខភាពរបស់ជនជាប់ចោទ និងការផ្តោតទៅលើការធ្វើសវនាការលើសំណុំរឿង[12]។*

[12] *រដ្ឋអាជ្ញា ទល់នឹង Jovica Stanišić*, សំណុំរឿងលេខ IT-03-69-T, សេចក្តីសម្រេចលើសំណើបន្ទាន់របស់មេធាវីការពារក្តី ស្នើសុំឲ្យមានការដាក់របាយការណ៍បន្ថែមទៀតពីសំណាក់អ្នកជំនាញពេទ្យផ្នែកចិត្តសាស្ត្រ និង សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំឲ្យធ្វើការកោសលុបខ្លះៗចេញពីកំណត់ត្រាវេជ្ជសាស្ត្រ (អង្គជំនុំជម្រះសាលាដំបូងតុលាការ ICTY), ៦ សីហា ២០០៩ ត្រង់កថាខណ្ឌ ១១។

១១- ដើម្បីកំណត់ថាតើ គេមូលហេតុគ្រប់គ្រាន់សម្រាប់ចោទជាសំណួរទាក់ទងនឹងសមត្ថភាពរបស់ជនជាប់ចោទថាបានយល់ច្បាស់អំពីដំណើរការនីតិវិធីដែរឬអត់ អង្គជំនុំជម្រះអាចគិតគូរមិនត្រឹមតែនៅលើកំណត់ហេតុវេជ្ជសាស្ត្រ និងមតិយោបល់របស់អ្នកជំនាញដែលមានស្រាប់ប៉ុណ្ណោះទេ ប៉ុន្តែអង្គជំនុំជម្រះថែមទាំងធ្វើការសង្កេតផ្ទាល់ខ្លួនលើជនជាប់ចោទ ទាំងនៅក្នុងអំឡុងពេល និងក្រោយពេលនៃកិច្ចដំណើរការនីតិវិធី។ អង្គជំនុំជម្រះនៃតុលាការ ICTY បានសម្រេចថា កត្តាទាំងឡាយដែលពាក់ព័ន្ធនឹងការវាយតម្លៃនេះ រួមមាន ថាតើជនជាប់ចោទ៖ (១) មានលទ្ធភាពធ្វើសេចក្តីថ្លែងផ្សេងៗជូនអង្គជំនុំជម្រះដោយផ្ទាល់ដែលសេចក្តីថ្លែងទាំងនោះ "ហាក់ដូចជាមានការចងក្រងយ៉ាងល្អ មានភាពពាក់ព័ន្ធ ត្រូវបានរៀបចំឡើងតាមរចនាសម្ព័ន្ធយ៉ាងប្រសើរ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយចំពោះអង្គជំនុំជម្រះដែរឬទេ"[13]; ២) ហាក់ដូចជាមានលទ្ធភាពក្នុងយល់ និងតាមដាននៅលើភ័ស្តុតាងដែលរួមមាន ការធ្វើកំណត់ហេតុជាសក្ខានុពល និងការយកចិត្តទុកដាក់ ដែរឬទេ"[14]; (៣) ហាក់ដូចជាបង្ហាញឲ្យឃើញថា ពួកគេកំពុងតែតាមដានលើកិច្ចដំណើរការនីតិវិធីតាមរយៈ ឧទាហរណ៍ការលើកឡើងពី "កង្វល់ដែលគាត់មិនអាចតាមដានកិច្ចដំណើរការនីតិវិធីបាន ដោយសារតែបញ្ហានៃឧបករណ៍ប្រព័ន្ធសោតទស្សន៍ និងការបញ្ចាំងវីឌីអូ ដែរឬទេ"[15]; (៤) បានធ្វើការណែនាំមេធាវីការពារក្តីរបស់ខ្លួនយ៉ាងសកម្ម ដែរឬទេ"[16] និង(៥) ជាទូទៅ "បានបញ្ចេញឥរិយាបថយ៉ាងល្អ និងសមរម្យដែរឬទេ"[17]។ អង្គជំនុំជម្រះមានឱកាសធ្វើការសង្កេតលើទង្វើររបស់ នួន ជា នាពេលថ្មីៗបំផុតគឺក្នុងអំឡុងនៃការធ្វើសេចក្តីសន្និដ្ឋានបិទការពិភាក្សាដេញដោល ក្នុងសំណុំរឿង ០០២/០១ ក្នុងខែតុលាឆ្នាំ២០១៣ ដែលនៅក្នុងអំឡុងពេលនេះ នួន ជា បានថ្លែងជូនតុលាការយ៉ាងច្បាស់ និងយ៉ាងប៉ិនប្រសប់អស់រយៈពេល៩០នាទី ចេញពីបន្ទប់សវនាការផ្ទាល់តែម្តង[18]។ តាមការសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ដោយកត់សម្គាល់ពីឥរិយាបថរបស់គាត់នៅក្នុងអំឡុងនៃសវនាការទាំងនោះ ពិតជាបានផ្តល់នូវសម្អាងហេតុជំទាស់ទៅនឹងការសាកសួរផ្សេងៗ អំពីសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការរបស់ នួន ជា។

---

[13] សេចក្តីសម្រេចក្នុងរឿងក្តី Strugar, កំណត់សម្គាល់*ខាងដើម* លេខ៤ ត្រង់កថាខណ្ឌ៥១។

[14] សេចក្តីសម្រេចក្នុងរឿងក្តី Strugar, *ខាងដើម* នៃកថាខណ្ឌ៥១។ សូមមើលផងដែរ *រដ្ឋអាជ្ញា ទល់នឹង Florencio Tacaqui,* សំណើរឿង លេខ: 20/2001, សាលក្រម (SPSC), ៩ ធ្នូ ២០០៤ ត្រង់ទំព័រ៩។

[15] សេចក្តីសម្រេចក្នុងរឿងក្តី Strugar, កំណត់សម្គាល់*ខាងដើម* លេខ៤ ត្រង់កថាខណ្ឌ៥១។

[16] សេចក្តីសម្រេចក្នុងរឿងក្តី Strugar, កំណត់សម្គាល់*ខាងដើម* លេខ៤ ត្រង់កថាខណ្ឌ៥១។

[17] សេចក្តីសម្រេចក្នុងរឿងក្តី Strugar, កំណត់សម្គាល់*ខាងដើម* លេខ៤ ត្រង់កថាខណ្ឌ៥១។

[18] **E1/237.1**, ប្រតិចារឹក អបជ, ៣១ តុលា ២០១៣ (នួន ជា), 09.03.56 - 09.57.28 និង 10.18.00 - 10.52.47។

១២- ការសំខាន់ គេត្រូវកត់សម្គាល់ថា មេធាវីការពារក្តី នួន ជា មិនបានអះអាងថា គាត់មិនមានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមក្នុងសវនាការទេ។ ផ្ទុយទៅវិញ ពួកគាត់គ្រាន់តែបានអះអាងថា សមត្ថភាពរបស់គាត់ក្នុងការផ្តោតការយកចិត្តទុកដាក់ឲ្យបានពេញលេញ និងជួយដល់មេធាវីការពារក្តី គឺមានកម្រិតត្រឹមតែ៩០នាទី និងចំនួនពេលវេលាជាក់លាក់នៃការអង្គុយក្នុងសវនាការក្នុងមួយសប្តាហ៍តែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងអនុម័តនូវកាលបរិច្ឆេទសម្រាប់សវនាការមានកម្រិតទៅតាមសំណើរបស់ក្រុមមេធាវីការពារក្តី ដោយកាលបរិច្ឆេទនេះជាក់ស្តែងត្រូវកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង តាមរយៈការដាក់បណ្តឹងឧទ្ធរណ៍ ដែលទំនងជានៅចុងឆ្នាំ២០១៤។ ដូច្នេះ ឧបាស្រ័យដែលបានស្នើឡើងដោយជនជាប់ចោទម្នាក់ៗ នឹងត្រូវបានបំពេញយ៉ាងពេញលេញ យ៉ាងហោចណាស់ក៏សម្រាប់រយៈពេលប្រាំបួនខែបន្ទាប់។ នៅពេលភាគីបានដាក់បណ្តឹងឧទ្ធរណ៍គ្រប់អស់ហើយ និងប្រសិនបើអង្គជំនុំជម្រះសាលាដំបូងត្រូវបានបង្ហាញឲ្យឃើញនូវភ័ស្តុតាងសំខាន់ៗពីបញ្ហាសមត្ថភាពរបស់ជនជាប់ចោទ ដើម្បីឲ្យមានការចាប់ផ្តើមមកអង្គុយក្នុងសវនាការពេញម៉ោង នោះបញ្ហានេះអាចនឹងត្រូវបានវាយតម្លៃឡើងវិញក្នុងពេលនោះតែម្តង។

ឃ. ដំណោះស្រាយដែលស្នើឡើង

១៣- អាស្រ័យដោយមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះសាលាដំបូង៖

ក. បដិសេធសំណើរបស់ នួន ជា ដែលស្នើឲ្យមានការពិនិត្យផ្នែកវេជ្ជសាស្ត្រគ្រប់ជ្រុងជ្រោយ

ខ. ទទួលយកសំណើរបស់មេធាវីការពារក្តី ដែលសុំឲ្យកាត់បន្ថយពេលវេលាសម្រាប់អង្គុយសម្រាប់សវនាការលើសំណុំរឿង ០០២/០២ ទូទាំងរយៈពេលនៃការធ្វើសេចក្តីព្រាងសាលក្រម ០០២/០១ ទាំងមូល និងរហូតដល់ពេលបញ្ចប់លើសេចក្តីថ្លែងសំអាងលើបណ្តឹងឧទ្ធរណ៍/បណ្តឹងសាទុក្ខដ៏មានសក្តានុពលណាមួយក្នុងសំណុំរឿង ០០២/០១; និង

គ. ពិចារណាថាតើ ជាការចាំបាច់ដែរឬទេដើម្បី កាត់បន្ថយពេលវេលានៅក្រោយពេលនោះ អាស្រ័យទៅតាមលក្ខខណ្ឌជាក់ស្តែងនៃវត្តមានរបស់ នួន ជា និង ខៀវ សំផន ដែលបានបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងពេលនោះ៕

កាលបរិច្ឆេទ	ឈ្មោះ	ទីកន្លែង	ហត្ថលេខា
ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៤	**លោកស្រី ជា លាង** សហព្រះរាជអាជ្ញា	ភ្នំពេញ	
	លោក Nicholas KOUMJIAN សហព្រះរាជអាជ្ញា		